**អភិបូជាខួប១២ឆ្នាំជាអភិបាល**

**ធ្វើនៅព្រះសហគមន៍សន្តយ៉ូសែប**

**ផ្សារតូច ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២**

**"សន្តសន្តិជាកម្លាំងសម្រាប់យើង ដើម្បីទៅជាមនុស្សសុចរិត"**

អត្ថបទទី១៖ សេរីភាព ១៧,៣-៧

តើព្រះអម្ចាស់គង់ក្នុងចំណោមពួកយើងមែន ឬមិនមែន? សរ ១៧,៧

**អត្ថបទទី២៖ រ៉ូម ៥,១-២.៥-៨**

យើងមានមាគ៌ាចូលទៅកាន់ជីវិតថ្មី។ រម ៥,២

**ដំណឹងល្អ៖ យ៉ូហាន ៤,៥-៤២**

តើលោកបានទឹកដែលផ្តល់ជីវិតនោះពីណាមក? យហ ៤,១១

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ យើងបានស្តាប់អំពីព្រះជាម្ចាស់ ច្រើនដងយើងសួរខ្លួនឯងថា **តើព្រះជាម្ចាស់ជានរណា?** ប៉ុន្តែ ថ្ងៃនេះពេលយើងស្តាប់អត្ថបទទី១ គឺគម្ពីរដំណើរឆ្ពោះទៅកាន់សេរីភាព ទំនាក់ទំនងលោកម៉ូសេជាមួយនឹងព្រះជាម្ចាស់ ណែនាំឱ្យយើងឃើញព្រះជាម្ចាស់ដូចជាសម្តែងព្រះហឫទ័យដល់លោកម៉ូសេនិងដល់យើងដែរ។ យើងបានស្តាប់ថា "**យើងជាព្រះដែលឪពុកអ្នកតែងគោរពបម្រើគឺព្រះរបស់លោកអប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុប**"។ នៅពេលយើងនឹកឃើញលោកអប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប យើងនឹកឃើញដល់លោកយ៉ូហានបាទីស្ទដែរ។ យើងនឹកឃើញដល់សន្តយ៉ូសែប ដែលយើងបានគោរពពីម្សិលមិញ ដោយសារទាំងអស់គ្នាជាមនុស្សសុចរិត។ ព្រះជាម្ចាស់បានជ្រើសរើសគេ ថែរក្សាគេ ឱ្យគេទទួលភាពដ៏វិសុទ្ធរបស់ព្រះអង្គទៅជាមនុស្ស សុចរិត ដែលរស់នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដ៏ពិតប្រាកដ។

តាមពិត នៅពេលខ្ញុំបានជ្រើសរើសថ្ងៃតែងតាំងជាអភិបាល ខ្ញុំបានរើសថ្ងៃសន្តយ៉ូសែប គឺថ្ងៃទី២០ ខែមីនា ឆ្នាំ២០១០។ ប៉ុន្តែ ថ្ងៃដែលព្រះជាម្ចាស់បានត្រាស់ហៅឱ្យខ្ញុំទៅជាលោកអភិបាល តាមរ

យៈសម្តេចប៉ាប បេណេឌីតូទី១៦គឺយប់បុណ្យព្រះយេស៊ូប្រសូត្រ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩។ ថ្ងៃដែលខ្ញុំបានទទួលបន្តបេសកកម្មដ៏ពេញលក្ខណៈពីលោកអភិបាល អេមីល គឺថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០គឺថ្ងៃសន្តីតេរេសា។ នៅក្នុងជីវិតរបស់យើង យើងមានសន្តសន្តីដែលណែនាំឱ្យយើងរស់នៅក្នុងព្រះហឫទ័យព្រះជាម្ចាស់។ យើងទាំងអស់គ្នា យើងមានគំរូដែលណែនាំឱ្យយើងទៅមុខនៅក្នុងជីវិតជាគ្រីស្តបរិស័ទ។ ប្អូនៗដែលថ្ងៃនេះធ្វើពិធីជម្រះចិត្តគំនិតលើកទី១ ប៉ុន្មានថ្ងៃមុន នៅពេលខ្ញុំត្រាស់ហៅយ៉ាងឱឡារិក ខ្ញុំបានហៅតាមឈ្មោះសន្តសន្តីដែលបានជ្រើសរើសផ្ទាល់ខ្លួន។ សន្តសន្តីជាកម្លាំងសម្រាប់យើង ដើម្បីទៅជាមនុស្សសុចរិត ប៉ុន្តែយើងត្រូវការធ្វើប្រយ័ត្ន។ យើងបានស្តាប់នៅក្នុងអត្ថបទទី២ "**ប៉ុន្តែ ដោយថាបុព្វបុរសមួយចំនួនធំ មិនបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ ពួកគេស្លាប់នៅវាលរហោស្ថាន**"។ តាមពិត យើងបានទទួលការត្រាស់ហៅទាំងអស់គ្នា ប៉ុន្តែជួនកាលយើងភ្លេចខ្លួន នៅពេលនោះដូចជាយើងស្លាប់នៅវាលរហោស្ថាន។ ប៉ុន្តែ ព្រះជាម្ចាស់គង់នៅជាមួយយើង ដើម្បីឱ្យយើងរស់ឡើងវិញសាជាថ្មី នេះជាបទពិសោធន៍ដែលខ្ញុំមាននៅក្នុងរយៈពេល១២ឆ្នាំកន្លងមក។

សន្ត អូក្ូស្តាំង ធ្លាប់មានប្រសាសន៍ថា "**ខ្ញុំជាលោកអភិបាលដើម្បីបម្រើបងប្អូន និងខ្ញុំជាគ្រីស្តបរិស័ទដែលធ្វើដំណើរជាមួយបងប្អូន**"។ ខ្ញុំគិតថា សម្រាប់ខ្ញុំជាលោកអភិបាលគឺនេះពិតមែន ខ្ញុំជាលោកអភិបាលដើម្បីបម្រើបងប្អូន នៅពេលខ្ញុំបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ខ្ញុំបានឆ្លាក់លើពែងកាលីសរបស់ខ្ញុំថា "**ដោយសេចក្តីស្រឡាញ់**"។ នៅពេលខ្ញុំបានទទួលអគ្គសញ្ញាតែងតាំងជាអភិបាលខ្ញុំបានឆ្លាក់ថា "**ដោយបម្រើ**"។ យើងជាលោកអភិបាលដើម្បីបម្រើបងប្អូន ប៉ុន្តែជាគ្រីស្តបរិស័ទដែរ ជាគ្រីស្តបរិស័ទម្នាក់ដែលដំណើររួមជាមួយបងប្អូន ជាបូជាចារ្យម្នាក់ដែលធ្វើដំណើររួមជាមួយលោកឪពុក ឱ្យយើងរួមគ្នាដើម្បីកសាងព្រះសហគមន៍នៅភូមិភាគភ្នំពេញ។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះយើងបានស្តាប់អត្ថបទដំណឹងល្អដែលស្តីអំពីស្ត្រីសាសន៍សាម៉ារី ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា "**ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ និងស្គាល់អ្នកដែលនិយាយទៅកាន់នាងថា ខ្ញុំសុំទឹកទទួលទានបន្តិច នោះនាងមុខជាសុំទឹកពីលោកវិញពុំខាន**"។ ប្រសិនបើនាងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ នេះជាបទពិសោធន៍ដែលខ្ញុំមាននៅក្នុងរយៈពេល១២ឆ្នាំ ដែលខ្ញុំបានធ្វើដំណើរជាមួយបងប្អូន។ ខ្ញុំបានមើលឃើញយ៉ាងជាក់ស្តែង អំពីព្រះអំណោយទានរបស់ព្រះជាម្ចាស់សម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គលើទឹកដីកម្ពុជា ជាពិសេសនៅក្នុងភូមិភាគភ្នំពេញ។ តាមរយៈមណ្ឌលសកម្មភាពទាំង៩ នៅពេលបានជួបជាមួយបងប្អូនគ្រីស្តបរិស័ទ ជួបជាមួយយុវជនយុវនារី ជួបជាមួយអ្នកដែលកំពុងស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ខ្ញុំបានឃើញយ៉ាងជាក់ស្តែង ពិតមែនព្រះអំណោយទាន

របស់ព្រះជាម្ចាស់ កំពុងកើតជារូបរាងនៅលើទឹកដីយើង។ យើងមានជីវិត យើងមានកម្លាំង ទោះបី មានកូវីដ-១៩ក៏ដោយ ក៏យើងបន្ត យើងបានធ្វើដំណើរនៅក្នុងការអធិដ្ឋានរួមជាមួយគ្នា ដើម្បីថែរក្សាជំនឿ។ ជំនឿរបស់យើង ជាជំនឿដែលយើងទទួលបានពីបុព្វបុរសរបស់យើង ដែលយើងទទួលថ្មីៗក៏ដោយ យើងដឹងថាជាជំនឿដែលយើងទទួលបានពីបងប្អូនដែលបានផ្តល់សក្ខីភាព ពីមុនសម័យប៉ុលពតរហូតដល់សម័យនេះ ដើម្បីឱ្យព្រះសហគមន៍ដែលបានឆ្លងប្រវត្តិសាស្រ្តដ៏ពិសេសនៅមានជីវិត។ នៅមានជីវិតដដែល កំពុងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃនៅក្នុងសេចក្តីសុខសាន្ត សម្រាប់នេះខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់។

ខ្ញុំអរព្រះគុណព្រះជាម្ចាស់ ពេលខ្ញុំឃើញព្រះអំណោយទានរបស់ព្រះអង្គតាមរយៈលោកបូជាចារ្យ បព្វជិតបព្វជិតា ដែលបម្រើព្រះសហគមន៍អស់ពីសេចក្តីស្រឡាញ់។ ដែលយកចិត្តទុកដាក់ធ្វើជាគ្រូគង្វាល ដើម្បីឱ្យព្រះសហគមន៍រួមរស់នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនធ្លាក់នៅក្នុងវាលរហោស្ថាន។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់ការអភិវឌ្ឍន៍ និងការប្រកាសដំណឹងល្អដែលយើងបានយកចិត្តទុកដាក់ធ្វើអស់រយៈពេល១២ឆ្នាំ។ ជាពិសេស តាមរយៈការិយាល័យនីមួយៗ ការិយាល័យយុវជន ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ការិយាល័យអប់រំជំនឿ និងពិធីបុណ្យ ការិយាល័យសុខភាពនិងកម្មករ ការិយាល័យការសិក្សា ការិយាល័យសិល្បៈ ការិយាល័យសហគ្រិនសង្គម ការិយាល័យទទួលស្វាគមន៍នៅភ្នំពេញថ្មី និងការិយាល័យលោកអភិបាល។ កន្លែងនីមួយៗ យើងមានតែបងប្អូនដែលយកចិត្តទុកដាក់នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងកម្លាំងកាយកម្លាំងចិត្ត ដើម្បីធ្វើដំណើរជាមួយគ្នា។

សព្វថ្ងៃ ពេលយើងនិយាយថាធ្វើដំណើរជាមួយគ្នា ខ្ញុំគិតថានៅក្នុងភូមិភាគយើង យើងមានបទពិសោធន៍នេះមែនទែន។ តាមកាលៈទេសៈនីមួយៗយើងទៅមុខទៀត នៅពេលយើងមានអំណរសប្បាយយើងទៅមុខ ពេលយើងចូលនៅក្នុងបញ្ហាជាមួយកូវីដ-១៩យើងទៅមុខទៀត។ សព្វថ្ងៃយើងខិតខំបន្តប្រកាសដំណឹងល្អ ដោយណែនាំឱ្យបងប្អូនរៀងៗខ្លួនអភិវឌ្ឍន៍ រីកចម្រើននៅក្នុងជីវិតរបស់គាត់។ ជាកុមារក្តី ជាយុវជនយុវនារីក្តី ជាពូមីងក្តី ជាតាយាយក្តី ដើម្បីរកឃើញអំណោយទានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតផ្ទាល់ខ្លួន។ ខ្ញុំបានឃើញ ព្រះអំណោយទានរបស់ព្រះជាម្ចាស់តាមរយៈអង្គការកាតូលិក និងតាមរយៈគ្រីស្តបរិស័ទដែលផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់។ ដែលជាសញ្ញាសម្គាល់ នៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង នៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ។ យើងមានវត្តមាន នៅក្នុងគ្រប់វិស័យ វិស័យអប់រំ វិស័យសុខភាព វិស័យអ្នកសង្គមកិច្ច វិស័យអភិវឌ្ឍន៍ជនបទ វិស័យដែលណែនាំឱ្យមនុស្សទាំងអស់អាចរកឃើញសេចក្តីសង្ឃឹម និងរកឃើញទីពឹងថ្មីនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ពិតមែន នៅគ្រប់

ទីកន្លែងក្នុងភូមិភាគភ្នំពេញ ក្នុងរយៈពេល១២ឆ្នាំកន្លងមកខ្ញុំបានមើល ខ្ញុំបានជួបជាមួយបងប្អូនដែលជាកម្លាំង កម្លាំងសម្រាប់ខ្ញុំដែលជាលោកអភិបាល ដោយសារខ្ញុំជាមនុស្សខ្សោយដែរយើងត្រូវការរកឃើញកម្លាំង។ កុំឱ្យយើងគិតថា យើងជាមនុស្សពោរពេញដោយកម្លាំងគ្រប់ពេលវេលា រកឃើញកម្លាំងសម្រាប់ព្រះសហគមន៍របស់យើង ដែលចេះតែទៅមុខ។ ជូនកាលយើងធ្លាក់ ជូនកាលយើងអស់សង្ឃឹម នៅពេលនឹកឃើញដល់ជីវិតដែលយើងមាននៅក្នុងភូមិភាគយើង ខ្ញុំមានតែអរព្រះគុណព្រះជាម្ចាស់។ ដោយសារ ពិតមែនប្រសិនបើយើងស្គាល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ យើងសុំទឹកពីព្រះយេស៊ូផ្ទាល់ ទឹកដែលផ្តល់ជីវិតអស់កល្បជានិច្ច។

បងប្អូនជាទីស្រឡាញ់ យើងចូលនៅក្នុងដំណើររួមជាមួយគ្នាតទៅទៀត ដើម្បីទៅខាងមុខ និងអរគុណសម្តេចប៉ាប ដែលបានសុំឱ្យព្រះសហគមន៍នៅក្នុងពិភពលោកទាំងមូល ចូលនៅក្នុងសន្និបាត២០២១-២០២៣ ដែលណែនាំឱ្យយើងគិតពិចារណា **តើយើងធ្វើដំណើររួមជាមួយគ្នាយ៉ាងដូចម្តេច?** ដោយយកចិត្តទុកដាក់នឹកឃើញដល់បេសកកម្មរបស់យើង យកចិត្តទុកដាក់ដើម្បីជាអង្គតែមួយ ធ្វើដំណើររួមជាមួយគ្នា ជាមួយព្រះជាម្ចាស់នៅក្នុងព្រះសហគមន៍របស់យើង។ ជាពិសេស ដើម្បីឱ្យយើងរៀងៗខ្លួនជាគ្រីស្តបរិស័ទក្តី ជាអ្នកដែលកំពុងស្វែងរកព្រះបន្ទូលព្រះជាម្ចាស់ក្តី ដែលជាយុវជនយុវនារី ដែលជាបូជាចារ្យ ដែលជាបងប្រុសបងស្រី ដែលជាលោកអភិបាល ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងបេសកកម្មដែលយើងបានទទួលពីព្រះជាម្ចាស់។ នៅក្នុងអត្ថបទទី១ យើងបានមើលឃើញរបៀបដែលយើងត្រូវតែធ្វើ ដោយសារកុំឱ្យយើងធ្វើតាមចិត្ត កុំឱ្យយើងធ្វើអ្វីតាមការនឹកឃើញ។ យើងត្រូវការចូលនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ចូលនៅក្នុងរបៀបដែលព្រះជាម្ចាស់ណែនាំយើង ដែលព្រះជាម្ចាស់បង្រៀនយើង ដែលព្រះជាម្ចាស់ធ្វើដំណើរជាមួយយើងតាំងពីដើមរៀងមក។

នៅពេលយើងនិយាយអំពី អង្គតែមួយ ធ្លុងតែមួយ យើងត្រូវការធ្វើយ៉ាងជាក់ស្តែង ព្រះជាម្ចាស់មានព្រះបន្ទូលថា "**ខ្ញុំជាព្រះដែលឪពុកអ្នកតែងគោរពបម្រើ គឺព្រះរបស់លោកអប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប**"។ ហើយយើងអាចថែម "**សន្តយ៉ូហានបាទីស្ត សន្តយ៉ូសែប ព្រះនាងម៉ារី សន្តសន្តីបុគ្គលទាំងឡាយ ជាព្រះជាម្ចាស់របស់យើង**"។ ដូច្នេះ នៅពេលនិយាយថាយើងជាអង្គតែមួយមុនគេបង្អស់យើងជាអង្គតែមួយនៅក្នុងព្រះជាម្ចាស់ នៅក្នុងព្រះជាម្ចាស់ដែលជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងព្រះជាម្ចាស់ ដែលធ្វើដំណើរជាមួយយើងពីព្រះអង្គបានជ្រើសរើសលោកតាអប្រាហាំ សព្វថ្ងៃជ្រើសរើសយើងដើម្បីឱ្យយើងចូលរួមនៅក្នុងមហាគ្រួសារនៃគ្រីស្តបរិស័ក្នុងពិភពលោកទាំងមូល។ អង្គតែមួយនៅក្នុងព្រះសហគមន៍សកល ជាមួយលោកអភិបាលទាំងឡាយ ជាមួយសម្តេចប៉ាប ជាមួយគ្រីស្តបរិស័ទទាំងមួយពាន់បីរយលាននាក់ ដែល

យើងមាននៅក្នុងពិភពលោក។ អង្គតែមួយនៅក្នុងភូមិភាគភ្នំពេញ រួមជាមួយបាត់ដំបង និងកំពង់ចាម នៅក្នុងព្រះសហគមន៍កាតូលិកកម្ពុជា ជាមួយព្រះសហគមន៍ឡាវ ជាមួយព្រះសហគមន៍នៅក្នុងទ្វីបអាស៊ី។ ជាពិសេស សម្រាប់យើងរួមជាមួយលោកអភិបាល យើងធ្វើដំណើរជាមួយគ្នាដើម្បីបង្ហាញថា ពិតមែននៅក្នុងព្រះយេស៊ូគ្រីស្ត នៅក្នុងព្រះជាម្ចាស់ដែលជាព្រះបិតា នៅក្នុងពន្លឺដែលជាព្រះវិញ្ញាណដ៏វិសុទ្ធ យើងជាអង្គតែមួយដើម្បីធ្វើដំណើរទៅមុខ។

បេសកកម្មរបស់យើង គឺឱ្យយើងស្ដាប់អ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលទៅលោកម៉ូសេថ្ងៃនេះ ព្រះបន្ទូលនេះជាព្រះបន្ទូលពិសេសបំផុត។ ដោយសារ ជាលើកទី១និងជាលើកចុងក្រោយដែរ ដែលព្រះជាម្ចាស់បង្ហាញព្រះនាមរបស់ព្រះអង្គទៅលោកម៉ូសេ។ នៅពេលនោះ តាមពិតអ្នកដែលនៅទល់មុខព្រះជាម្ចាស់ត្រូវតែស្លាប់ ប៉ុន្តែលោកម៉ូសេនៅពេលនោះមិនស្លាប់ទេ។ លោកម៉ូសេបានស្ដាប់ព្រះបន្ទូលនេះ "**អ្នកត្រូវប្រាប់ជនជាតិអ៊ីស្រាអែលថា យើងជាព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ**"។ នេះជាព្រះនាមរបស់ព្រះជាម្ចាស់ ជាព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ នៅពេលយើងទទួលដំណឹងនេះ យើងយល់អំពីបេសកកម្មរបស់យើង។ យើងយល់អំពីអ្វីដែលយើងត្រូវតែធ្វើពីមួយថ្ងៃទៅមួយថ្ងៃ គឺណែនាំឱ្យព្រះជាម្ចាស់ដែលមានព្រះជន្មគង់ នៅភ្ជាប់ជាមួយយើងផ្ទាល់ភ្ជាប់ជាមួយបងប្អូនឯទៀតៗ។ យើងនឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ "**ខ្ញុំយាងមកនៅក្នុងពិភពលោកនេះ ដើម្បីណែនាំឱ្យបងប្អូនមានជីវិត ជីវិតដ៏បរិបូរណ៍**" *យ៉ូហាន ១០,១០*។

ខ្ញុំគិតថា ប្រសិនបើយើងត្រូវការសរុបបេសកកម្មរបស់យើងយ៉ាងខ្លីបំផុត សម្រាប់យើងដែលជាគ្រីស្តបរិស័ទ សម្រាប់យើងដែលជាបូជាចារ្យ សម្រាប់យើងដែលជាបុព្វជិតបុព្វជិតា សម្រាប់យើងដែលជាការិយាល័យក្នុងភូមិភាគរបស់យើង សម្រាប់យើងដែលជាអង្គការកាតូលិក យើងត្រូវតែណែនាំឱ្យព្រះជន្មរបស់ព្រះជាម្ចាស់ទៅដល់បងប្អូន។ ឱ្យបងប្អូនមានជីវិតជីវិតដ៏បរិបូណ៌ ជីវិតដែលមកពីព្រះជាម្ចាស់ដើម្បីធ្វើដំណើរទៅមុខ ធ្លាក់ឡើងទៅ អស់សង្ឃឹមមានសង្ឃឹមវិញ ធ្លាក់ទឹកចិត្តមានកម្លាំងសាជាថ្មី អត់មានទីពឹងមានទីពឹងវិញ។ ដូចស្ត្រីសាម៉ារី គាត់លាក់ខ្លួនដល់ម៉ោង១២ថ្ងៃត្រង់ទើបគាត់ទៅដងទឹក ដោយសារគាត់ដឹងថាម៉ោងហ្នឹងអត់មានអ្នកភូមិដែលនៅ ព្រោះក្តៅពេក។ ស្ត្រីសាម៉ារី គាត់ពោរពេញដោយបញ្ហា គាត់មានប្តីច្រើនណាស់ ប៉ុន្តែដោយសារគាត់បានជួបជាមួយព្រះយេស៊ូផ្ទាល់ គាត់បានទទួលជីវិត ជីវិតដ៏ពិតប្រាដក ជីវិតដ៏ពេញលក្ខណៈ។ ណែនាំឱ្យគាត់ទៅជាមនុស្សថ្មី ណែនាំឱ្យគាត់លែងខ្មាស់គេ ណែនាំឱ្យគាត់រត់ដល់ភូមិដើម្បីប្រកាសថា "**ខ្ញុំបានជួបព្រះសង្គ្រោះហើយ ខ្ញុំបានជួបព្រះជាម្ចាស់ដែលមានជីវិត ជីវិតអស់កល្បជានិច្ច សុំមកសុំមកមើលព្រះអង្គ**" នេះជាបេសកកម្មរបស់យើង។

យើងធ្វើដូចម្ដេចដើម្បីចូលរួមយ៉ាងសកម្ម ចូលរួមយ៉ាងសកម្មតាមរបៀបរបស់ព្រះជាម្ចាស់ ថ្ងៃនេះ យើងត្រូវតែរំភើបនៅពេលយើងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលបង្ហាញអំពីរបៀបរបស់ព្រះអង្គផ្ទាល់ខ្លួន។ "**យើងជាព្រះដែលបានឃើញទុក្ខលំបាករបស់ប្រជារាស្ត្រយើងនៅស្រុកអេហ្ស៊ីប យើងក៏បានឮសម្រែករបស់គេ ព្រោះតែអ្នកត្រួតត្រាវាយដំ យើងដឹងអំពីទុក្ខវេទនារបស់ពួកគេ ដូច្នេះយើងចុះមកដើម្បីរំដោះពួកគេឱ្យរួចពីកណ្ដាប់ដៃរបស់ជនជាតិអេស៊ីប**"។ នៅនេះ យើងយល់យ៉ាងច្បាស់អំពីរបៀបដែលយើងចង់ចូលរួមយ៉ាងសកម្ម ឱ្យយើងមើលឃើញជីវិតប្រចាំរបស់បងប្អូន ជីវិតរបស់យើងនៅក្នុងសង្គមបច្ចុប្បន្ននេះ នៅក្នុងពិភពលោកនេះ។ ដែលសព្វថ្ងៃយើងភ័យខ្លាចដែរសម្រាប់អនាគត យើងឃើញចេញពីកូវីដ-១៩ចូលនៅក្នុងសង្គ្រាម ត្បិតតែសង្គ្រាមនៅឆ្ងាយប៉ុន្តែបានជះឥទ្ធិពលដល់យើង។ បន្តិចម្ដងៗពិបាកទៅៗ យើងភ័យខ្លាចដូច្នេះឱ្យយើងចេះមើលឃើញ ប៉ុន្តែមិនមែនត្រឹមតែមើលឃើញឱ្យយើងចេះស្ដាប់ឮ ស្ដាប់ឮទុក្ខលំបាករបស់បងប្អូន ស្ដាប់ឮសេចក្ដីសង្ឃឹមរបស់គេដែរ។ ឱ្យយើងទទួលស្គាល់ ដូចព្រះជាម្ចាស់ទទួលស្គាល់ពិតមែន អ្នកនោះអ្នកនេះ មិនមែនទូទៅៗ។ ពេលព្រះយេស៊ូពេលធ្វើដំណើរ ទោះបីមានមហាជនច្រើនក៏ដោយ នៅពេលដល់កន្លែងលោកសាខេព្រះយេស៊ូទតឃើញលោកសាខេ។ ពេលមានស្ត្រីដែលធ្លាក់ឈាមយូរឆ្នាំហើយប៉ះពាល់ព្រះអង្គ ព្រះយេស៊ូមើលឃើញគាត់។ ព្រះយេស៊ូមិនមែនដូចមនុស្សទូទៅទេ ព្រះយេស៊ូមើលម្នាក់ៗ ដោយសារព្រះយេស៊ូមើលឃើញ ស្ដាប់ឮ និងទទួលស្គាល់។ ក្រោយមក យើងចេញសមត្ថភាព យើងចេញសកម្មភាពដូចព្រះយេស៊ូ "**ដូច្នេះយើងចុះមកដើម្បីរំដោះពួកគេ**"។

តាមរយៈព្រះសហគមន៍របស់យើង នៅក្នុងគណៈកម្មការសង្គហៈ តាមរយៈអង្គការនីមួយៗ តាមរយៈកម្មវិធីអប់រំសិក្សា តាមរយៈកម្មវិធីយុវជនយុវនារី តាមរបៀបដែលយើងផ្សព្វផ្សាយ។ យើងមានឱកាសច្រើនដើម្បីចុះពិតប្រាកដមែន ចុះដល់មូលដ្ឋាន ចុះដល់កន្លែងដែលបងប្អូននៅ។ យើងឃើញនៅព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច ទោះបីក្នុងវដ្ដរសៃសិបថ្ងៃនេះ ប៉ុន្មានដងបានទៅដល់កន្លែងដែលបងប្អូនមានទុក្ខលំបាក អ្នកជំងឺក្ដី អ្នកដែលកំពុងស្លាប់ក្ដី អ្នកក្រីក្រក្ដី ឱ្យយើងចុះ។ ប៉ុន្តែ កុំឱ្យយើងទម្លាក់លើគណៈកម្មការសង្គហៈ ដោយសារយើងរៀងៗខ្លួនយើងជាគណៈកម្មការសង្គហៈដ៏តូចមួយ។ យើងជាព្រះជាម្ចាស់ដ៏តូចមួយ ដែលត្រូវតែបង្ហាញធម៌មេត្តាករុណាដល់បងប្អូនឯទៀតៗផ្ទាល់ អ្នកជិតខាង បងប្អូនដែលយើងស្គាល់ នៅក្នុងអំណរសប្បាយនៃព្រះជាម្ចាស់។ នេះជាផ្លូវរបស់ព្រះជាម្ចាស់ នេះជាផ្លូវដែលយើងត្រូវបន្តរួមជាមួយគ្នា ដើម្បីបង្កើតព្រះសហគមន៍នៅលើទឹកដីភូមិភាគភ្នំពេញ ឱ្យព្រះសហគមន៍របស់យើងមានជីវិត។ ដោយសារ ម្នាក់ៗជាថ្មដ៏មានជីវិត នៅពេលទទួលពិធីជ្រមុជទឹកយើងនឹកឃើញនេះ យើងជាថ្មដ៏មានជីវិត។ ដូច្នេះ អគារដែលយើងកំពុងធ្វើយ៉ាងស្អាត ដើម្បីមានអភិបូជាយ៉ាងផ្លូវការនិងឱឡារិកឆាប់ៗនេះ

តែអ្វីដែលសំខាន់ឱ្យបងប្អូនរៀបចំខ្លួនយ៉ាងស្អាតបំផុតដែរ រួមជាមួយលោកបូជាចារ្យ រួមជាមួយបងប្រុសបងស្រី រួមជាមួយលោកអភិបាល ដើម្បីឱ្យយើងទាំងអស់គ្នាអាចរស់នៅក្នុងព្រះហឫទ័យព្រះជាម្ចាស់។ នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ យើងអាចទៅជាមនុស្សសុចរិត។

បងប្អូនជាទីស្រឡាញ់ មានតែពាក្យមួយម៉ាត់ដើម្បីបញ្ចប់ធម្មទេសនានេះ គឺអរគុណដល់បងប្អូន អរព្រះគុណដល់ព្រះជាម្ចាស់។ យើងបន្តធ្វើដំណើរជាមួយគ្នា ដើម្បីឱ្យព្រះសហគមន៍របស់យើងទៅជាសញ្ញាសម្គាល់ នៃព្រះជន្មរបស់ព្រះយេស៊ូ "**ពិតមែនខ្ញុំយាងមកដើម្បីឱ្យគេមានជីវិត ជីវិតដ៏បរិបូណ៌**"។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មឺតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/bIC43SfQ6nA